ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី ពិធីចុះហត្ថលេខាលើ «កម្មវិធីផ្លាស់ប្តូរវប្បធម៌»
## រវាង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាល នៃសាធារណរដ្ឋឥណ្ឌា

ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៣ វេលាម៉ោង១៩ នៅវិមានសន្តិភាព ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីជំនាញជាន់ខ្ពស់ជាតិ និងអន្តរជាតិ បានប្រារព្ធពិធីចុះហត្ថលេខាលើ **«កម្មវិធីផ្លាស់ប្តូរវប្បធម៌»** រវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាល នៃសាធារណរដ្ឋឥណ្ឌា ក្នុងបំណងរួមគ្នាបង្កើត និងអភិវឌ្ឍន៍នូវទំនាក់ទំនងវប្បធម៌ឲ្យកាន់តែជិតស្និទ្ធថែមទៀត ជាពិសេសលើវិស័យសិល្បៈវប្បធម៌ សម្រាប់រយៈពេល៣ឆ្នាំ ចាប់ពីឆ្នាំ ២០១៣ ដល់ឆ្នាំ ២០១៥។

កម្មវិធីផ្លាស់ប្តូរវប្បធម៌នេះ ត្រូវបានចុះហត្ថលេខាដោយ **ឯកឧត្តម ហ៊ឹម ឆែម** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នៃព្រះរាជាណាចក្រកម្ពុជា និង **លោកជំទាវ សានហ្គីតា ហ្គៃរ៉ូឡា** អនុរដ្ឋមន្ត្រី ក្រសួងវប្បធម៌ នៃសាធារណរដ្ឋឥណ្ឌា។

សារៈសំខាន់នៃកម្មវិធីផ្លាស់ប្តូរវប្បធម៌នេះគឺ៖ ១) ផ្លាស់ប្តូរទស្សនកិច្ចសិក្សា លើអ្នកជំនាញផ្នែកបណ្ណសារ បណ្ណាល័យ សិប្បកម្ម រចនាសម្ភារៈតាំងពិព័រណ៍ ភាពយន្តមហោស្រព សារមន្ទីរ សារព័ត៌មាន និងជំនាញផ្សេងៗទៀតដែលពាក់ព័ន្ធទៅនឹងវិស័យវប្បធម៌។ ២) បង្កើតគម្រោងស្រាវជ្រាវរួមគ្នាក្នុងការបកប្រែផ្នែកអក្សរសិល្ប៍ និងផ្លាស់ប្តូរអ្នកនិពន្ធទៅវិញទៅមក ព្រមទាំងបញ្ជូនអ្នកស្រាវជ្រាវ ដើម្បីចូលរួមស្រាវជ្រាវរួមគ្នាក្នុងវិស័យវប្បធម៌នៃប្រទេសទាំងពីរ។ ៣) ផ្លាស់ប្តូរក្រុមសិល្បៈទស្សនីយភាព រៀបចំសប្តាហ៍ភាពយន្ត និងបង្កើតកម្មវិធីព្រឹត្តិការណ៍វប្បធម៌ផ្សេងៗទៀត។

តាមរយៈកម្មវិធីផ្លាស់ប្តូរវប្បធម៌ ដែលបានចុះហត្ថលេខានាថ្ងៃនេះ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នៃព្រះរាជាណាចក្រកម្ពុជា សង្ឃឹមថានឹងអាចស្នើសុំកិច្ចសហប្រតិបត្តិការពីភាគីឥណ្ឌាក្នុងការជួសជុលប្រាសាទបុរាណមួយចំនួន នៅក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់រយៈពេលវែងថែមទៀត។

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៣